# សេចក្តីប្រកាសព័ត៌មាន
# កម្មវិធីអប់រំតាមវិទ្យុ ជួយឱ្យសិស្សជនជាតិដើមភាគតិចអាចបន្តការសិក្សា បើទោះសាលារៀនកំពុងបិទទ្វារក៏ដោយ

**រាជធានីភ្នំពេញ ថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១៖** ក្រសួងអប់រំ យុវជន និងកីឡា និងយូនីសេហ្វ កំពុងសហការគ្នាធានាឱ្យកុមារគ្រប់រូប ជាពិសេសកុមារដែលជួបការលំបាក និងមានឱកាសតិចតួច បន្តទទួលបានការសិក្សា ខណៈដែលសាលារៀនត្រូវបិទទ្វារចំពេលមានការឆ្លងជំងឺកូវីដ-១៩ ក្នុងសហគមន៍ នាពេលបច្ចុប្បន្ននេះ។ យូនីសេហ្វ បានទិញវិទ្យុចំនួន ១.៦៤០ គ្រឿង សម្រាប់ផ្តល់ជូនសិស្សជនជាតិដើមភាគតិចនៅខេត្តភូមិភាគឦសាន គឺខេត្តក្រចេះ រតនគិរី និងមណ្ឌលគិរី។ សិស្សទាំងនេះកំពុងបន្តការសិក្សារបស់ពួកគេ តាមរយៈកម្មវិធីអប់រំពហុភាសាផ្សាយតាមវិទ្យុ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលជាទម្រង់មួយ ក្នុងចំណោមទម្រង់នៃការសិក្សាពីចម្ងាយដែលក្រសួងអប់រំ យុវជន និងកីឡា ចាប់ផ្តើមអនុវត្ត តាំងពីពេលមានការរាតត្បាតជាសកលនៃជំងឺនេះពីដំបូងៗមកម្ល៉េះ។

ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានមានប្រសាសន៍ថា "ក្នុងអំឡុងពេលដ៏សែនលំបាកនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលក្រសួងអប់រំ យុវជន និងកីឡា អាចសហការជាមួយយូនីសេហ្វ និងភាពជាដៃគូសកលសម្រាប់ការអប់រំ ដើម្បីផ្តល់ឱកាសសិក្សាពីចម្ងាយ ដែលជាតម្រូវការចាំបាច់បំផុតរបស់កុមារជនជាតិដើមភាគតិច ដែលកំពុងទទួលបានការអប់រំពហុភាសា។ ដើម្បីសម្រេចបានលទ្ធផលពិតប្រាកដពីកម្មវិធីអប់រំពហុភាសាតាមវិទ្យុ វាជាការសំខាន់ណាស់ដែលមាតាបិតាត្រូវជួយឱ្យកូនៗរបស់ពួកគេបន្តរៀនសូត្រ តាមរយៈការប្រើប្រាស់សេវាអប់រំដ៏មានតម្លៃនេះ។"

កម្មវិធីអប់រំពហុភាសាតាមវិទ្យុ ផ្តល់ការបង្រៀនតាមវិទ្យុដល់សិស្សដែលកំពុងទទួលបានការអប់រំពហុភាសានៅកម្រិតមត្តេយ្យ និងបឋមសិក្សាជាភាសាគ្រឹង និងភាសាទំពួន ក្នុងខេត្តរតនគិរី និងភាសាព្នងក្នុងខេត្តមណ្ឌលគិរី។ មានសិស្សប្រមាណ ១.៥២៧ នាក់មកពីសាលាបឋមសិក្សាចំនួន ៧៩ ដែលបច្ចុប្បន្ននេះពុំមានវិទ្យុប្រើប្រាស់ នឹងទទួលបានវិទ្យុមួយគ្រឿង ដែលធ្វើឱ្យគេអាចនាំយកការបង្រៀននេះទៅដល់ក្នុងផ្ទះរបស់ពួកគេតែម្តង។ លើសពីនេះ គ្រូមត្តេយ្យសហគមន៍ពហុភាសាចំនួន ៣៤នាក់ និងគ្រូបឋមសិក្សាពហុភាសា ៧០នាក់ ក៏នឹងទទួលបានវិទ្យុសម្រាប់ប្រើប្រាស់ក្នុងការបង្រៀនរបស់ពួកគេក្នុងថ្នាក់រៀន ឬក្នុងអំឡុងពេលចុះអនុវត្តសកម្មភាពរៀន និងបង្រៀនពីចម្ងាយផងដែរ។ វិទ្យុទាំងនេះនឹងត្រូវចែកជូនពួកគេ នៅដើមខែមេសា។

លោកស្រី ហ្វ័រហ្គ ហ្វយូហ្សិថ នាយិកាយូនីសេហ្វប្រចាំកម្ពុជា បានមានប្រសាសន៍ថា "យូនីសេហ្វមានមោទនភាពដែលបានធ្វើការងារក្នុងភាពជាដៃគូជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា និងភាពជាដៃគូសកល

សម្រាប់ការអប់រំ ក្នុងការអនុវត្តកម្មវិធីអប់រំពហុភាសាតាមវិទ្យុ ដែលកំពុងផ្តល់ប្រយោជន៍ទៅដល់កុមារដែលងាយរងគ្រោះជាងគេនៅកម្ពុជា និងជួយឱ្យពួកគេបានបន្តការសិក្សា។ ការផ្តល់វិទ្យុដល់កុមារទាំងនេះ នឹងជួយពង្រីកវិសាលភាពកម្មវិធីអប់រំពហុភាសាបន្ថែមទៀត ដែលមានសារៈសំខាន់ក្នុងអំឡុងពេលដែលសាលារៀនកំពុងបិទទ្វារ។ នេះគឺជាគំនិតផ្តួចផ្តើមដ៏សំខាន់មួយ ដែលជួយឆ្លើយតបចំពោះបញ្ហានៃការខកខានការរៀនសូត្រ ដោយសារតែផលប៉ះពាល់ដែលបង្កឡើងដោយសារជំងឺកូវីដ-១៩”។

កម្មវិធីអប់រំពហុភាសាតាមវិទ្យុកំពុងអនុវត្តតាមរយៈកិច្ចខិតខំប្រឹងប្រែងឆ្លើយតប និងស្តារឡើងវិញពីជំងឺកូវីដ-១៩ នៅកម្ពុជា ជាមួយនឹងការផ្តល់មូលនិធិគាំទ្រពីភាពជាដៃគូសកលសម្រាប់ការអប់រំ។ យូនីសេហ្វ គឺជាទីភ្នាក់ងារចាត់ចែងថវិកាសម្រាប់កម្មវិធី ដែលមានទឹកប្រាក់៧លានដុល្លារនេះ ដែលកំពុងផ្តល់ការគាំទ្របន្ទាន់ដល់សាលារៀន និងសិស្សានុសិស្សក្នុងអំឡុងពេលដែលមានការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩។

<u>កំណត់សម្គាល់សម្រាប់និពន្ធនាយក៖</u>

**អំពីយូនីសេហ្វ៖**

យូនីសេហ្វកម្ពុជាធ្វើការងារ ដើម្បីលើកកម្ពស់ការអភិវឌ្ឍល្អប្រសើររបស់កុមារ ការពារសិទ្ធិរបស់ពួកគេ និងជួយឱ្យពួកគេសម្រេចសក្តានុពលចាប់ពីវ័យកុមារតូច រហូតដល់វ័យក្មេងជំទង់។ សម្រាប់ព័ត៌មានបន្ថែមអំពីយូនីសេហ្វ និងការងារដែលយូនីសេហ្វធ្វើដើម្បីកុមារ សូមចូលមើលគេហទំព័រ www.unicef.org/cambodia/ ។ សូមតាមព័ត៌មានអំពីយូនីសេហ្វ Twitter និង Facebook

**អំពីភាពជាដៃគូសកលសម្រាប់ការអប់រំ (GPE)៖**

ភាពជាដៃគូសកលសម្រាប់ការអប់រំ (GPE) គឺជាការប្តេជ្ញាចិត្តរួមដើម្បីបញ្ចប់វិបត្តិការសិក្សារបស់ពិភពលោក។ យើងកៀរគរដៃគូ និងមូលនិធិ មកគាំទ្រប្រទេសមានចំណូលទាបចំនួន៧៦ ក្នុងគោលបំណងកែលម្អប្រព័ន្ធអប់រំ ដើម្បីឱ្យកុមារី និងកុមារាគ្រប់រូបអាចទទួលបានការអប់រំប្រកបដោយគុណភាពដែលពួកគេត្រូវការ សម្រាប់ឈានទៅសម្រេចសក្តានុពលពេញលេញរបស់ខ្លួន និងចូលរួមចំណែកកសាងពិភពលោកឱ្យល្អប្រសើរជាងមុន។ ជាមួយបទពិសោធជិត២០ឆ្នាំក្នុងការជួយប្រទេសដៃគូ ក្នុងការគាំទ្រដល់កុមារី និងកុមារាក្នុងប្រទេសខ្លួនឱ្យបានចូលសាលា និងរៀនសូត្រ GPE បានជំរុញ និងលើកទឹកចិត្តដល់គ្រូបង្រៀន សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ ស្ថាប័នសហប្រជាជាតិ ធនាគារអភិវឌ្ឍន៍ ក្រុមហ៊ុនជំនួញ និងមូលនិធិសប្បុរសធម៌ ឲ្យគាំទ្រដល់ភាពជាអ្នកដឹកនាំរបស់ប្រទេស

ដៃគូ ក្នុងការផ្តល់ដំណោះស្រាយហិរញ្ញវត្ថុ និងការគាំទ្រ ដើម្បីធានាថាពុំមានកុមារណាម្នាក់ត្រូវបានគេមិនយកចិត្តទុកដាក់។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**


- ឯកឧត្តមបណ្ឌិត រស់ សុវាចា អ្នកនាំពាក្យក្រសួងអប់រំ យុវជន និងកីឡា
  ទូរស័ព្ទ៖ +៨៥៥ ៧៨ ៧៥៥ ៥៥៦ ឬសារអេឡិចត្រូនិក៖ soveacha2002@yahoo.com
- អ្នកស្រី រូឌីណា វ៉ូដា ប្រធានផ្នែកទំនាក់ទំនង យូនីសេហ្វ
  ទូរស័ព្ទ៖ (+៨៥៥) ៩២ ៥៥៥ ២៩៤ ឬ សារអេឡិចត្រូនិក៖ rvojvoda@unicef.org
- លោក មាស ប៊ុនលី មន្ត្រីជំនាញផ្នែកទំនាក់ទំនង យូនីសេហ្វ
  ទូរស័ព្ទ៖ +៨៥៥ ១២ ៧៣៣ ៩០៩  ឬសារអេឡិចត្រូនិក៖ bmeas@unicef.org
- អ្នកស្រី ថាម៉ារ៉ា គូមមឺ ភាពជាដៃគូសកលសម្រាប់ការអប់រំ
  ទូរស័ព្ទ៖ +៣៣ ៧ ៨២ ២៦ ០៧ ១៨ ឬសារអេឡិចត្រូនិក៖ tkummer@globalpartnership.org